BMI0187

# សម្ភាសន៍ជាមួយឈ្មោះ វ៉ាន់ សូវី ភេទស្រី
## មុខងារនៅសម័យខ្មែរក្រហមៈ “ប្រជាជនធ្វើការកងចល័ត”
## រស់នៅភូមិប៉ុស្តិ៍ចាស់ ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ
## ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១១
## សម្ភាសន៍ដោយៈ ចាន ប្រុញ
## ០០:៥៦:៤៣
## ១៨ទំព័រ

សូវី ៖ ខ្ញុំនៅភូមិប៉ុស្តិ៍ចាស់ ឃុំព្រះនេត្រព្រះ នៅសម័យ៧៤ ខ្ញុំការប្តីនៅសៀមរាប ដល់ឆ្នាំ៧៥ ប៉ុល ពត ខ្ញុំនៅសៀមរាបបានយូរគ្រាន់ ដល់៧៦-៧៧ បានចេញពីហ្នឹងមក ដឹងតែម៉ែខ្ញុំនៅភូមិប៉ោយក្បឿង ដឹងតែម្តាយឪពុកអីខ្ញុំគេជម្លៀសទៅភូមិប៉ោយក្បឿង ។

ប្រុញ ៖ ឆ្នាំ៧៤ អ្នកមីងនៅសៀមរាបទេ?

សូវី ៖ ចាស៎

ប្រុញ ៖ ពេលនៅសៀមរាប ម៉េចបានអ្នកមីងមកនេះដែរ?

សូវី ៖ ពេលក្រុមគ្រួសារខ្ញុំនៅនេះអស់ទៅ ដល់ម៉ែក្មេក ប្តីអីគេយកទៅវៃចោលអស់ទៅ ខ្ញុំក៏រត់មក ។

ប្រុញ ៖ គេវៃគាត់ចោលឆ្នាំណាដែរអ្នកមីង?

សូវី ៖ មិនដឹងថាឆ្នាំណាទេ ដឹងតែឆ្នាំ ប៉ុល ពត ចូល ។

ប្រុញ ៖ កាលហ្នឹងនៅសៀមរាប?

សូវី ៖ ចាស៎ នៅសៀមរាប ។

ប្រុញ ៖ ឪពុកម្តាយបង្កើត?

សូវី ៖ ទេ! ឪពុកម្តាយបង្កើតក្មេក ។

ប្រុញ ៖ ប្តីគេសម្លាប់ពេលហ្នឹងឯង?

សូវី ៖ ចាស៎ បាត់ទាំងអស់នោះឯង ។

ប្រុញ ៖ ហេតុអីបានគេសម្លាប់គាត់អ្នកមីង?

សូវី ៖ អត់ដឹងដែរ ។ ដូចគេសួរថា ពួកនិស្សិតរៀនថ្នាក់ទីប៉ុន្មានៗអីណា សព្វថ្ងៃយើងថានិស្សិតបាក់អង បាក់ឌុប គេចង់និយាយពីអីចេះឯង ។

ប្រុញ ៖ ដល់ពេលអ្នកមីងបាត់បង់គ្រួសារអីចឹងទៅ ក៏បានមករស់នៅ...?

សូវី ៖ ខ្ញុំអត់ទាន់រត់មកទេ ទៅនៅចល័តជាមួយគេឡើងឃួរ លើកទំនប់អីចេះដែរ ពេលលើកទំនប់មានគេអ្នកប្ញែកដឹងអំពៅជីកអី សួរថាគេនៅឯណា? គេនៅស្វាយសិសុផុន ប៉ោយប៉ែតសួរគេថា អ្នកមានស្គាល់អ្នកព្រះនេត្រព្រះ ម៉ែខ្ញុំនៅព្រះនេត្រព្រះ គេឆ្លើយថា អ្នកព្រះនេត្រព្រះមានផាប់ច្រើន មិនដឹងថាប៉ះអ្នកណាៗទេ។ ដល់ថ្ងៃក្រោយមកខ្ញុំជួបបងសុង បងសុងគាត់ធ្វើឈ្លបនៅស្រុកក្រឡាញ់ ជីកអំពៅទៅ ជីកចុងអំពៅ ដល់ខ្ញុំសួរបងសុងទៅ គាត់ស្គាល់ច្បាស់ ព្រោះប៉ែ តុ បងគាត់នៅជាមួយម៉ែខ្ញុំ គាត់ថាម៉ែឯងនៅប៉ោយកឿងជាមួយពួកប៉ែតុអ៊ំខ្ញុំ ម៉ែវាអីនៅទាំងអស់គ្នា ខ្ញុំថាមិនដឹងម៉េចបានទៅស្រុកទេ ដល់នេះទៅ ខ្ញុំលួចរត់មុនដំបូងរត់ទៅជាមួយឈ្មោះ លី គេបបួលរត់មក ឯងទៅៗ អញស្គាល់តាមផ្លូវ ខ្ញុំក៏ទៅដែរ។ ដល់មកដល់ មិនទាន់បានឆ្លងស្ទឹងក្រឡាញ់ផង អត់ហ៊ានមកតាមផ្លូវត្រង់ទេ មកតាមផ្លូវស្ទឹង ដល់ចុះមក មកជួប អ៊ំវ៉ា អ៊ំវ៉ាថានៅស៊ីបាយនេះសិនហើយ បងសុងថា អាវីកុំទៅវិញអី នៅស្រុកយើងណោះ គេរើអត់រើសមុខទេ កុំថាឡើយតែនេះ ទែអ្នករៀនដល់ឌីប្លូមអីក៏គេចាប់វៃចោលដែរ ខ្ញុំថា ខ្ញុំនឹកម៉ែណាស់ ខ្ញុំស៊ូមិនបានទេ ឲ្យខ្ញុំទៅៗ។

ប្រុញ ៖ ពេលហ្នឹងអ្នកមីងរៀនដល់ថ្នាក់ទីប៉ុន្មានដែរ?

សូវី ៖ ខ្ញុំរៀនដល់ថ្នាក់ទី៦ចាស់ ជិតមកប្រឡងហើយហ្នឹង។ រត់មកទៅគាត់ប្រាប់អីចេះឯង គាត់អត់ឲ្យមកទេ ខ្ញុំថាចុះឲ្យខ្ញុំទៅណាវិញ បើជិតមកដល់ម៉ែហើយ ទៅមិនបានទេ ស្រណោះថានៅក្មេងពេក គាត់ឲ្យស៊ីបាយហើយ ក៏ឆ្លងស្ទឹងទៅវិញ ដល់ឆ្លងស្ទឹងទៅវិញ ឈ្លបគេមកចាប់បណ្ដោយ តែខ្ញុំអត់ស្គាល់ឈ្លបអីទេ គេមកចាប់ មិនដឹងថាយោធាស្អីទេ គេចាប់ គេចេះសួរថានាងឯងនៅឯណា? ខ្ញុំថា ខ្ញុំនៅព្រះនេត្រព្រះ ក៏រៀបរាប់ប្រាប់គេ គេថានៅក្មេងយ៉ាងនេះ ម៉េចក៏ហ៊ានរត់ ខ្ញុំប្រាប់ថា ខ្ញុំនឹកម៉ែខ្ញុំ ដល់ហើយទៅគេសួរដំណើរដើមទង មុនដំបូងយើងអត់ហ៊ាននិយាយបញ្ជាក់ច្បាស់ត្រង់នេះត្រង់នោះ យើងគ្រាន់តែប្រាប់ថា ខ្ញុំមករៀននៅសៀមរាប ដល់មកនៅសៀមរាបខ្ញុំនឹកម៉ែខ្ញុំ ខ្ញុំក៏រត់ ទៅគេថា នាងឯងអត់ដឹងទេ នេះពួកសន្តិសុខណា៎ ខ្ញុំថាសន្តិសុខយ៉ាងណា ខ្ញុំអត់ដែលស្គាល់ទេ បើមិនស្គាល់មែន។ សន្តិសុខដូចថាអ្នកទោសធ្ងន់អីដឹង ទៅគេថាយកទៅនៅកន្លែងកុមារកំព្រា នៅវត្តដំដែក ដល់ទៅៗ ប្រធានយោធាធំគេនៅនោះមួយ ឈ្មោះ គា ខ្ញុំស្គាល់ឈ្មោះគាត់។

ប្រុញ ៖ ប្រធានយោធាឈ្មោះ គា?

សូវី ៖ ចាស៎

ប្រុញ ៖ គាត់ធ្វើអីគេនៅហ្នឹង?

សូវី ៖ គាត់ក្តាប់មួយស្រុកសូត្រនិគមណា ។

ប្រុញ ៖ ដល់ពេលគេចាប់យើងទៅអីចឹង គេឲ្យយើងធ្វើអីគេអ្នកមីង?

សូវី ៖ យើងនៅក្មេងពេក គេអត់ឲ្យធ្វើអីទេ ។ កាលពីមុនយើងលើកទំនប់លើកអី ដល់ពេលយើងរត់មកនេះ គេអាណិតដូចថាមើលទៅក្មេងគួរឲ្យអាណិត ក៏គេមិនធ្វើអីទេ ។

ប្រុញ ៖ កាលហ្នឹងអ្នកមីងអាយុប៉ុន្មាន?

សូវី ៖ អាយុ ១៦ឆ្នាំ ។

ប្រុញ ៖ ដល់ពេលចេញពីដីដែកហ្នឹងមក មកណាវិញ?

សូវី ៖ ដល់ពេលនេះទៅ មានឡានគេមកដឹកអំពៅ ដឹកចុងអំពៅទៅដាំ បងគា គាត់សួរថា បើម៉ែពុកឯងនៅមិនបានទេ ចាំបងធ្វើសំបុត្រឲ្យ ធ្វើសំបុត្រទៅហៅមកវិញប្អូនអត់ ។ បើសិនជាខ្ញុំធ្វើសំបុត្រឲ្យ តើឯងរកម៉ែពុកឯងឃើញប្អូនអត់? ខ្ញុំថារកឃើញ ហើយចុះឯងចាំភូមិប្អូនអត់? ខ្ញុំថាចាំ ។ ម៉ែខ្ញុំរើពីប៉ុស្តិ៍ចាស់ មកនៅប៉ោយក្បៀង ក្រុមគ្រួសារអ៊ំខ្ញុំអីមកនៅប៉ោយក្បៀងទាំងអស់ ខ្ញុំនិយាយប្រាប់គេណា អ៊ីចឹងគេឲ្យមក គាត់ធ្វើសំបុត្រឲ្យមក លិខិតចារឲ្យមកដូចថាក្នុងមួយខែ បើសិនជាយើងមកលេងឪពុកម្តាយ យើងឈប់នឹកហើយទៅវិញក៏ទៅចុះមកនៅកន្លែងគាត់ទៅ គាត់មិនឲ្យធ្វើការអីធ្ងន់ធ្ងរទេ ព្រឹកឡើងឲ្យរើសពងទាដែលពងពេញណាពេញណី គេឲ្យយើងរើសដាក់កញ្ចេ ជួយមើលគេឯណេះឯណោះទៅ ក៏គេឲ្យយើងស៊ីតែបាយនៅហ្នឹង ។ ដល់ពេលខ្ញុំមកដល់ដប់ ជិះឡានជាមួយគេមកដល់ដប់ ក៏ឡានគេឈប់ ខ្ញុំមករកម៉ែខ្ញុំនៅខែប្រូត គេចុះទៅប្រូតឆ្ងាយ មកដល់ជួបអ្នកកើ គេថាទាំងអស់គ្នាម៉េចក៏ហ៊ានមក យាយខ្ញុំដែលខូច គាត់ថាម៉េចក៏ហ៊ានមកកូនអើយៗកូន ខ្ញុំថាខ្ញុំនឹកម៉ែស៊ូមិនបាន អ្នកកើថា ឯងនៅនេះហើយ ចាំអញទៅតាមម៉ែឯង គាត់ទៅប្រូតនៅឆ្ងាយ នៅស៊ីងកំបុត ។ ដល់នេះម៉ែខ្ញុំមក ខ្ញុំថានេះសំបុត្រម៉ែ គេឲ្យមកលេង បើមួយខែ ខ្ញុំឈប់នឹកម៉ែនឹកឪ ទៅណោះរដ្ឋចិញ្ចឹម គាត់ថាអ្នកណា? ខ្ញុំថាបងគា គេប្រធានស្រុក ឬក៏យោធាមិនដឹង បើមិនស្គាល់នោះ ។ នៅមិនទាន់បានមួយខែផង បានតែមួយអាទិត្យ គេបញ្ជូនទៅនៅត្រពាំងថ្ម ។

ប្រុញ ៖ អត់បានទៅធ្វើការដ្ឋានវិញទេ?

សូវី ៖ អត់បានទៅកន្លែងវិញទេ ។ ដឹងតែមកបានមួយអាទិត្យ ដូចប្រធានភូមិគេ ឈ្លបគេនៅនេះណា៎ គេបញ្ជូនយើងទៅកម្លាំងទី១ភ្ជាម គេបញ្ជូនទៅត្រពាំងថ្ម ។

ប្រុញ ៖ ទៅត្រពាំងថ្ម ប្រហែលជាឆ្នាំណាដែរអ្នកមីង?

សូរី ៖  អូ! មិនដឹងទេ វវេង្វងអស់ហើយ ។

ប្រុញ ៖ អ៊ីចឹងអត់បានទៅធ្វើនៅកំពោរព្រែះអីទេ?

សូរី ៖  អត់ទេ! គេបញ្ជូនទៅត្រពាំងថ្ម ខ្សែត្រៀមទី១ម្តង ។

ប្រុញ ៖ ទៅដំបូង មានគេចាប់ផ្តើមធ្វើប្រុនៅ?

សូរី ៖  ទេ! មានគេចាប់ផ្តើមធ្វើពីណោះមក ដូចថាធ្វើពីណោះមក ដេញទៅអ៊ីចេះណា ។

ប្រុញ ៖ អ៊ីចឹងត្រពាំងថ្ម មានគេធ្វើបណ្តើរៗហើយ?

សូរី ៖  ទេ! ត្រពាំងថ្ម ខ្ញុំចាប់ធ្វើពីខាងលិចស្ពានទៅអ៊ីចេះ ទៅដល់បានវែកខាងលិចស្ពានទៅ គេឲ្យចាប់គូចេះឯង ពីរម៉ែត្រគូបកន្លះដូចថាអ៊ីចេះឯង ដូចថាគេចាប់គូ ទៅដល់អ្នកភ្នំពេញម្នាក់នេះឈ្មោះ បងយោង គាត់នៅនេះ បងគាត់គេយកទៅសម្លាប់ គាត់ខ្លាច គាត់នៅកងចល័តព្រោះមាឌគាត់ធំ ។ បងយោងហ្នឹង គាត់ទូរស័ព្ទពីភ្នំពេញមកថា គាត់នៅកន្លែងលូទឹកស្អុយថាប្តីគាត់ធ្វើរដ្ឋមន្ត្រី ប្តីគាត់ឈ្មោះ យ៉េង ។ គាត់ហ្នឹងឯងមាឌធំ គាត់ឃើញខ្ញុំរាងនេះគាត់ស្រណោះតើ អ៊ី អារី មិនបាច់ចាប់គូជាមួយអ្នកណាទេ ចាប់គូជាមួយខ្ញុំមក ថាអ៊ីចេះ ។ ម៉ាក្រុមខ្ញុំនោះ មួយឈ្មោះ បងញ៉ី សុទ្ធតែអ្នកភ្នំពេញទេ អត់មានអ្នកប្រជាជនចាស់ទេខ្ញុំនេះដូចអ្នកប្រជាជនជម្លៀសពីភ្នំពេញអ៊ីចេះឯង គេចាត់ទុកខ្ញុំអ៊ីចឹងឯងមិនដឹង បានជាគេឲ្យខ្ញុំទៅ មួយបងញ៉ី ពីរ បងវ៉ាន់ បីបងយោង មួយទៀតខ្ញុំហៅគាត់ថាអ៊ុំមួយៗ គាត់និយាយអត់សូវច្បាស់ទេ ដូចចិនអ៊ីចេះឯង ។ ដល់តែពេលទៅៗ ក្នុងក្រុមខ្ញុំមាន១០នាក់ បងយោងគាត់ស្រណោះខ្ញុំ គាត់ថា អារី អើយបើសិនវែកបីម៉ែត្រគូប កាយៗដាក់ឲ្យអញមក ហើយមាឌគាត់ដូចមនុស្សប្រុសអ៊ីចឹង ពេលឃើញតែខ្ញុំរាងខ្សោយ គាត់កាប់តែពីរប៉ុិបដឹងតែពេញបង្គី ហើយគាត់វែកឡើងទាល់តែខ្ពស់ គាត់វែកឡើងរួច តែរួចហើយគាត់មិនហ៊ានឈប់មុនគេទេ អត់ហ៊ានឲ្យរួចទេ ទុកសល់ពីរបីអម្រែក គ្រាន់វែកដំណាលនឹងគេ ជិតដល់វែកខ្សែត្រៀម ដូចថាខ្សែត្រៀមអ៊ីចេះវាជាប់នៅណាំតាវ យើងលើករាងគងអ៊ីចេះ គងពីត្រពាំងថ្មអ៊ីចេះទៅជាប់ណាំតាវ ទៅឈប់នៅព្រៃណាំតាវនោះឯង ឈប់លើកទំនប់ណាំតាវទៅជាប់នឹងគេនៅ ខាងនោះមកគេលើកនៅកំពីងកំពួយ គេវៃមកអ៊ីចេះ យើងវៃទៅអ៊ីចេះ ។

ប្រុញ ៖ ណាំតាវគេលើកដែរ?

សូរី ៖  ចាស៎ ណាំតាវ ខ្សែត្រៀមគេវៃមកពីនោះ គេហៅស្រុកស្ទឹងត្រង់ណាទេ ខ្ញុំអត់ស្គាល់ទេ ។ ដល់ពេលយប់នោះ ថៃមួយ គាត់ខានទៅធ្វើការមួយថ្ងៃ សួរគាត់ទៅ គាត់ថាឈឺក្បាលស្រាប់តែនេះគេថាឲ្យទៅដេកពេទ្យ បងយោង ដែលថានៅភ្នំពេញសព្វថ្ងៃគាត់ដឹង គាត់

និយាយថា អាវីឯងកុំឆោត ឯងនៅល្ងង់ណាស់ ទៅដេកពេទ្យនេះ មិនមែនទៅដេកពេទ្យទេ គេយកទៅសម្លាប់ហើយ ខ្ញុំថា គេយកទៅសម្លាប់អី បើគាត់ឈឺគេយកទៅពេទ្យហើយ គាត់ថាមិនមែនទៅដេកពេទ្យទេ ។ ដល់ទៅពេលយប់នោះទៅ គាត់ទំមូរកន្ទេលដាច់ប្រវែងនេះណា៎ គាត់មានចិញ្ចៀនពេជ្រ បីគ្រាប់ ប៉ុនរឿងមាសអីគាត់មានប៉ុន្មានៗ ខ្ញុំអត់ដឹងទេណា៎ ខ្ញុំដឹងតែគាត់ពាក់ចិញ្ចៀននោះឯង ហើយអាកូនវាឃើញថាត្បូងស វាដែលទៅថាល្អ វាថាយើងពាក់ចិញ្ចៀនក្លែងក្លាយអីដឹង វាអត់យកទេ ហើយគាត់ថា អាវីអើយបងអត់មានអនុស្សាវរីយ៍អីទេ បងឲ្យចិញ្ចៀននេះ ខ្ញុំថា ខ្ញុំអត់យកទេ គេមិនឲ្យចាយប្រាក់ចាយអី ចិញ្ចៀននេះខ្ញុំអត់យកទេ បងមួយឯងយកទៅ ដល់បងមួយឯងទៅដេកពេទ្យទៅ មានអ្នកណាគេយកអីមកដូរ បងមួយឯងដូរហូបទៅ ព្រោះថ្ងៃមុនបងដោះក្រវិលមួយដី ដូរស្វាយបានប្រាំមួយ ខ្ញុំប្រាប់គាត់ណា៎ ហើយយកគាត់ទៅបាត់ទៅយប់នោះ ។ គាត់យំអើយយំ បងយោងគាត់យំទាំងអស់គ្នា ខ្ញុំថាយំធ្វើអី ខ្ញុំចេះតែថាអីចឹងឯង បាត់បងមួយ អត់ឃើញមកចូលកងវិញទេ ។

ប្រុញ ៖ ពេលហ្នឹងហូបម៉េចដែរអ្នកមីង?

សូវី ៖ ហូបបបរ អត់មានម្ហូបអីទេ ពេលថ្ងៃយើងចុះពីធ្វើការ យើងស៊ីបបរលាយជាមួយដើងគោ បេះត្រួយស្លឹកដើងគោស៊ី ។

ប្រុញ ៖ យើងហូបពេលថ្មើម៉ាន?

សូវី ៖ ពេលយើងធ្វើការ យើងស៊ីបបរដូចជាមិនសូវពេញពោះ យើងចេះតែបេះស៊ី ដល់ពេលល្ងាចមក បើយើងមានសព្វថ្ងៃយើងថាស៊ីផ្លែឈើលេងណា៎ តែអានេះយើងស៊ីស្លឹកឈើ អត់ស៊ីផ្លែឈើទេ ។ ក្រោយមកទៀត ក្រុមខ្ញុំវិលងបាន១២ថ្ងៃ បាត់បងវ៉ាន់ ខ្ញុំឮគេនិយាយថា បងវ៉ាន់នេះកូនសក្តិ៥ នៅភ្នំពេញ គាត់មានបងប្អូន៣នាក់ ប៉ុលពតគេនិយាយថា ឥឡូវនេះខ្ញុំរកបងប្អូនឪពុកមិត្តឯងឃើញហើយ និយាយប្រាប់គាត់ណា កាលដែលគាត់ជម្លៀសមក ខ្ញុំអត់ដឹងថាគាត់នៅភូមិណាទេ កងចល័តនៅជុំគ្នា ខ្ញុំមិនបានសួរគាត់ថា ម៉ែឪនៅភូមិណាទេ ។ គេយកបងវ៉ាន់ គេដកពីកងចល័តឲ្យទៅជួបម៉ែឪ ខ្ញុំចេះតែឆ្ងល់បងវ៉ាន់ចាំឃើញសិនចាំទៅៗ គាត់ខ្សឹបប្រាប់ភ្លាម បងវ៉ាន់សំណាំតែគាត់រៀនខ្ពស់បានគាត់ដឹង គាត់ថាកុំសង្ស័យអី បើសិនជាគេដកបងទៅ គេយកបងទៅវៃចោល ខ្ញុំមិនជឿថាគេយកគាត់ទៅវៃចោលទេ ស្រាប់តែដល់យប់នោះ ប្រហែលជាម៉ោង៨កន្លះ គេយកគាត់ទៅ ស្រាប់តែបាន៣-៤ថ្ងៃ ខ្ញុំឮគេនិយាយថាបងវ៉ាន់គេយកទៅវៃចោលនៅព្រៃស្អីទេ ថានៅជើងភូមិណាំតាវ នៅក្នុងព្រៃ ។ មួយក្រុមខ្ញុំគ្រាន់តែចប់ទំនប់កំពីងកំពួយ ចាំមើលនិយាយមួយក្រុមខ្ញុំ ក្រុមដទៃមិនបានតាមដាន មិន

បានស្គាល់ឈ្មោះគេទេ អ្នកដែលងាប់ៗណា ខ្ញុំស្គាល់តែបងញ៉ អ៊ីមួយ បងវ៉ាន់ នេះនៅក្នុងក្រុមខ្ញុំ នៅសល់តែ៧នាក់ ។

ប្រុញ ៖ ក្រុមហ្នឹងអ្នកណាគេជាអ្នកដឹកនាំក្រុមអ្នកមីង?

សូវី ៖ មិនដឹងទេ មិនដឹងជាអ្នកណាប្រធានក្រុមទេ អាចឈ្មោះបងឡាច ។

ប្រុញ ៖ ប្រធានកង?

សូវី ៖ ប្រធានកង រឹតតែមិនស្គាល់គេទៀត ប្រធានកងដូចត្រឹមតែយើងស្គាល់គេតិចៗទៅ ស្រាប់តែដល់បន្តិចដូរទៅទៀតទៅណា ។ ដូចថានេះប្រធាន ប្រធាននេះឈ្មោះអ៊ី ឈ្មោះរ៉េត មិនទាន់តែស្គាល់ រ៉េត បាន៤-៥ថ្ងៃ ក៏គេដូរ រ៉េត ទៅណាទៀតបាត់ទៅណា ។

ប្រុញ ៖ ចុះអ្នកមីងមានដឹងថាអ្នកណាគេជាអ្នកគ្រប់គ្រងធំនៅការដ្ឋានត្រពាំងថ្មទេ?

សូវី ៖ ពេលនោះឮគេថា តាវ៉ាល់ តាម៉ោង ប៉ិអាត ឮតែអ៊ីចឹងឯង មិនដឹងថាមុខវាយ៉ាងណាទេ មិនដែលឃើញមុខទេ ដឹងតែប៉ុណ្ណឹងឯង ។

ប្រុញ ៖ ចុះនៅហ្នឹងគេឈឺច្រើនទេអ្នកមីង?

សូវី ៖ មានឈឺតើ ហើយកូនអ្នកភ្នំពេញឈ្មោះ ញិញ ដល់មកដល់កន្លែងដើមពោធិ៍អត់មានស្លឹកទេ ដើមពោធិ៍វ៉ាងៗណា ដល់យើងឡើងពីខ្សែត្រៀមមួយទៅអ៊ីចេះទៀតណា ចុះបើគេឲ្យយើងដើរយប់នោះ ទៅដល់គេថាស្នាក់នៅនេះហើយ ក្រុមខ្ញុំដេកនៅជុំវិញដើមពោធិ៍ទាំងស្រីទាំងប្រុសណា ដាក់បន្ទីនាំគ្នាដេក ស្រាប់តែដល់ពេលម៉ោង៣ហើយ ត្រូវពេលក្រោកទៅធ្វើការហើយ ញិញនោះឯង គាត់សស្គុះ ដាសគាត់ គាត់ស្វាយអស់ ងាប់ ។ ខ្ញុំសួរគេថា គាត់កើតអីបានគាត់ងាប់ គេថាកុំសួរណា ប្រយ័ត្នងាប់ទាំងអស់គ្នា គាត់មិនហ៊ានសួរទេ ដល់នេះទៅបងយោងគាត់ខ្សឹបថា ប្រហែលជាពស់ចឹកហើយ ឃើញគាត់ដេកហ្នឹងបៀតរន្ធចេញដើមពោធិ៍ គាត់ថាអ៊ីចេះ បានខ្ញុំថាអាណិតគាត់ណាស់ គាត់ស្វាយអស់ ស្វាយជើង ស្វាយដៃអស់ ។

ប្រុញ ៖ ចុះខ្លួនគាត់មានស្នាមពស់ចឹកទេ?

សូវី ៖ អ្នកណាហ៊ានមើល គេដែលទៅឲ្យយើងមើល បើដាសអ្នកនេះដើបថាចេញៗៗ គេដេញយើងចេញណា៎ គេមិនឲ្យយើងនៅមើលថាអ៊ីចេះអ៊ីចុះទេ គេមិនឲ្យយើងនៅទេ គេថាចេញឲ្យលឿនៗៗ ចុះដល់ម៉ោងធ្វើការគេជម្លៀសយើងចេញ គេមិនឲ្យយើងរត់ទៅមើលអ៊ីចេះអ៊ីចុះអី អត់បានទេ បើតាមប្រុសៗថាពស់ចឹកនោះឯង ។

ប្រុញ ៖ ហ្នឹងពេលហើយត្រពាំងថ្មអ្នកមីង?

សូរី ៖ ចាស៎ ពេលហើយយើងឆ្លងទៅខ្សែត្រៀមណាំគាវ ។

ប្រុញ ៖ ពេលត្រពាំងថ្ម មានពេទ្យនៅហ្នឹងទេអ្នកមីង?

សូរី ៖ មាន!

ប្រុញ ៖ មានពេទ្យនៅប្រចាំការនៅហ្នឹងដែរ?

សូរី ៖ មិនដឹងជាប្រចាំអីទេ តិចទៅឃើញគេមក សែងថ្នាំ សែងទឹក ពេទ្យអាពតគេហៅទឹកស្ពីទេ យើងថាដាំទឹកដឹកអនាម័យនោះណា គេថាទឹកស្ពីទេ ដាក់ប៉ុសឈើផង សន្កមកិច្ចគេថាទឹកស្ងោរថ្នាំឲ្យយើងដឹក ។

ប្រុញ ៖ ទឹកហ្នឹងម៉េចដែរ ទឹកមានអនាម័យទេអ្នកមីង?

សូរី ៖ ទឹកធម្មតាយើងហូបនោះឯង អានោះសម្រាប់ពេទ្យគេសែងមកណា តែដល់នេះយើងដឹកទឹកគេចែក អ៊ីចឹងទេគេឃុំយើង ដូចថា១០នាក់ ប្អូនឯងសុខចិត្តកាត់ឲ្យបង អ្នកនេះកាត់ឲ្យបងទៅក៏ចំណាយឲ្យបងមួយ ក៏វែកទឹក ។

ប្រុញ ៖ វែកទឹកឆ្ងាយទេ?

សូរី ៖ ចាស៎ ឆ្ងាយ ។ បើត្រពាំងថ្មមានស្រះមួយ មានដើមត្នោត មើលទៅថាឆ្ងាយ ពីនេះដល់ស្រះ ២គីឡូកន្លះ ៣គីឡូអីទៅណា ចុះទៅវែកទឹក ហើយទឹកនៅនោះមិនល្អទេ ទឹកល្អក់វិល ។

ប្រុញ ៖ បើនិយាយឲ្យចំទៅកាលនៅត្រពាំងថ្ម គេចែកឲ្យយើងម្នាក់ពីរម៉ែត្រកន្លះ ត្រូវទេអ្នកមីង?

សូរី ៖ ចាស៎ ពីរម៉ែត្រកន្លះ ។

ប្រុញ ៖ ហើយដល់ពេលយើងនៅជាមួយគ្នា១០នាក់ អ៊ីចឹង១០នាក់ហ្នឹង ៩នាក់ជួយធ្វើការ ហើយម្នាក់ទៀតទៅវែកទឹក?

សូរី ៖ ចាស៎ វែកទឹកហ្នឹង យើងនៅជាមួយគ្នាទេណា យើងនៅធ្វើដដែល ដូចអាអូនឯងមកជួយបន្តិចនេះជួយបន្តិចទៅណា៎ ហើយតែប្រើចំណាយមនុស្សម្នាក់ហើយ យើងត្រូវតែជួយគ្នា ។

ប្រុញ ៖ ចុះបើអត់មានអ្នកណាទៅសែង បានអ្នកណាសែងឲ្យយើងហូប?

សូរី ៖ មានអ្នកណាគេសែងឲ្យយើងហូប ។

ប្រុញ ៖ អង្ករគេអត់យកមកឲ្យយើងហូបទេ?

សូរី ៖ ទេ! អង្ករគេចែកទឹកយើងតិចៗហ្នឹង ។

ប្រុញ ៖ ជាទូទៅបើយើងអត់ទៅធ្វើ គេចែកខ្លះដែរអត់ទេ?

សូរី ៖ មានអ្នកណាគេចែកទឹក គេមិនបានចែកឲ្យយើងទេ ដោះស្រាយខ្លួនឯងទឹក មិនស្គាល់ត្រពាំងឯណា ចេះតែដើរសួរគេទៅណា ទឹកឃើញចែកមួយស្វាបព្រាបីដង ចែកទឹកដួសស្វាបព្រា

ទៀវណា ស្វាបព្រាសយើងប៉ុនដូចលាបថ្នាំ ហើយគេដួសចែកទៅណា ដូចថាចានបបរយើង ដាក់អីចេះ គេឈរខ្ពស់ជាងយើង គេដួសចាក់មកទៅណា ចាក់បបរ តែបើទឹកអាកន្ទែងអត់ មិនដឹង ខ្មែរក្រៀមធំគេចែកទឹក២ដង ៣ដង បានដឹកទឹកហ្នឹង៣ដង គ្រាន់តែចែកកូនស្វាបព្រា តូចមួយហ្នឹង ។

ប្រុញ ៖ អ៊ីចឹងពេលហ្នឹង បើសិនជាយើងទៅជងខ្លួនឯងចម្ងាយ២-៣គីឡូអី?

សូរី ៖ ជួនកាល២-៣គីឡូ គេមិនដែលឲ្យយើងទៅជងទេ យើងលួចទៅណា៎ ដូចថាយើងអត់ទឹកខ្លាំង អាអូនឯងមានកូនកាម៉ែលតូចមួយមក ខ្ញុំក៏មានកូនកាដុងតូច គេថាអាវីទៅជងទៅ ចំណាយឲ្យ ខ្ញុំម្នាក់ទៅជងទៅណា មើលទៅម៉ែត្រគូបយើងជិតរួចហើយ យើងសន្សឹមថាម្នាក់បានពីរម៉ែត្រ គូបហើយៗ ឲ្យទៅជងទៅ គ្នាយើងហ្នឹងណា ។

ប្រុញ ៖ ពេលយើងទៅជង បើសិនជាគេចាប់បានម៉េចដែរ?

សូរី ៖ គេសួរយើងដែរតើ គេសួរថាទៅណា? ខ្ញុំថាខ្ញុំទៅជងទឹក ។ រួចម៉ែត្រគូបហើយនៅ? ខ្ញុំថា ម៉ែត្រគូបខ្ញុំរួចហើយ ខ្ញុំទៅជងមួយក្រុម មិនមែនដឹកតែឯងទេ ពេលទៅជងទឹកហ្នឹង ពេល យើងឃើញទឹក បានផ្លូតបានអីទេ គេមិនឲ្យយើងផ្លូតទេណា ។

ប្រុញ ៖ នៅស្រះហ្នឹងមានគេយាមទេ?

សូរី ៖ មាន! យើងរាងខ្លាចគេដែរ ឃើញគេអង្គុយស្លៀកពាក់ខ្មៅ ក៏ខ្លាចគេ មិនហ៊ានសួរគេទេ ជួន កាលយើងខ្លាចខ្លួនយើងទៅ យើងអត់ហ៊ានផ្លូតទេណា បានមួយកាដុងស្រោចលើខ្លួនយើង មួយកាដុងទៀតវែកមកអ៊ីចឹងទៅណា ។

ប្រុញ ៖ ពេលយើងធ្វើការភ្ជួរ គេបានចែកទឹកឲ្យយើងមួយសារដែរ?

សូរី ៖ មិនដែលចែកទឹកទេ ពេលខ្មែរក្រៀមដែលអត់ខ្លាំង គេបានទឹកពីណាទេ គេចែកដួសស្វាបព្រា ឲ្យ ។

ប្រុញ ៖ អ៊ីចឹងអ្នកនៅហ្នឹងអត់មានបានផ្លូតបានអីទេ ធ្វើការនៅការដ្ឋានហ្នឹង?

សូរី ៖ គ្មានអ្នកណាបានផ្លូតទឹកទេ ស្រីៗ ។ បើគ្រពាំងថ្មយើងបានផ្លូតទឹកខ្លះ ទឹកវាល្អក់ យើងបាន ផ្លូតបន្តិចទៅណា បើកូនខ្វែងអត់សោះ ។

ប្រុញ ៖ អ្នកមីងធ្លាប់បានធ្វើកូនខ្វែងដែរ?

សូរី ៖ ខ្ញុំធ្វើហួសទៅអីចេះ អ្នកចូលខ្មែរក្រៀមកូនខ្វែងអីចេះ ខ្ញុំធ្វើទៅអីចេះ មុខព្រួញដូចតែគ្នានោះ ឯង ប៉ុនគ្រាន់តែខុសគ្នា យើងទៅអីចេះ គេទៅអីចេះ ។

ប្រុញ ៖ ចុះដល់ពេលគេស្នាក់នៅៗណាមីង?

សូរី ៖ ស្នាក់តាមក្រោមដើមឈើអីចឹងទៅ ។

ប្រុញ ៖ ពេលធ្វើនៅត្រពាំងថ្ម?

សូរី ៖ នៅត្រពាំងថ្ម មានដើមពោធិ៍ ដើមស្វាយទេ ខ្ញុំភ្លេចហើយ យូរពេក ។

ប្រុញ ៖ គេឲ្យយើងស្នាក់នៅហ្នឹង ចុះស្នាក់នៅម៉េចអស់គ្នា នៅដើមពោធិ៍សោះ?

សូរី ៖ យើងរកកន្លែងដូចថា មានឈើកម្ពស់ប៉ុណ្ណេះ យើងចេះតែអង្គុយជ្រកទៅ យើងទៅរកស្រួល ម៉េច បើគេឲ្យយើងធ្វើអីចុះឯង ។

ប្រុញ ៖ គេមានធ្វើរោងឲ្យយើងដេកពេលយប់អត់?

សូរី ៖ អត់មានរោងទេ ពួកខ្ញុំធ្វើហ្នឹងអត់ដែលមានរោងទេ ។

ប្រុញ ៖ ចុះហេតុអី បានកន្លែងខ្លះគេធ្វើឲ្យដេក កន្លែងខ្លះអត់?

សូរី ៖ ដូចថាកន្លែងរោងដេក ជួនកាលមានកន្លែងពេទ្យគេ កន្លែងដូចថាគេហៅការដ្ឋាន កន្លែងពេទ្យ ណា ។

ប្រុញ ៖ អីចឹងគេមិនមែនធ្វើរោងឲ្យយើងតាមមុខព្រួញ យើងកាប់មួយកន្លែងគេធ្វើរោងឲ្យជាប់គ្នា?

សូរី ៖ អត់ទេ គ្មានទេ ។

ប្រុញ ៖ ទៅធ្វើហ្នឹងយូរទេអ្នកមីងនៅត្រពាំងថ្ម?

សូរី ៖ មិនដឹងប៉ុន្មានខែ ដឹងតែរួចខ្សែត្រៀម គេធ្វើមិទ្ទីងទាំងអស់គ្នា អ្នកដែលធ្វើទំនប់ទាំងអស់គ្នា ។

ប្រុញ ៖ ហ្នឹងពេលចប់ត្រពាំងថ្ម?

សូរី ៖ ពេលចប់រហូតដល់ណាំតាវ កំពីងកំពួយ ចាក់មកពីណោះ យើងចាក់ទៅពីនេះ ដូចថា នេះទំនប់ គេមិនចាក់មកអីចេះ ហើយយើងចាក់ទៅពីនេះ ដល់ពេលយើងចប់ គេហៅចាប់ដៃ គ្នា យើងចាក់ជួបគ្នាទល់មុខគ្នា គេណោះច្រើនដែរ យើងរាប់រយរាប់ពាន់ដូចតែគ្នាណា៎ ដល់ តែជួបគ្នាទៅ គេធ្វើមិទ្ទីង ។

ប្រុញ ៖ មិទ្ទីងហ្នឹងម៉េចទៅ?

សូរី ៖ មិទ្ទីងហ្នឹងគេសម្ពោធ គេរាំសិល្បៈ ដូចថាគេឆ្លើយឈ្មោះ ប៉ុនយើងមិនស្គាល់គេ ខ្ញុំអង្គុយតែ មើលទៅណា ។

ប្រុញ ៖ សិល្បៈហ្នឹង គេលេងពីអីគេអ្នកមីង?

សូរី ៖ មិនដឹងទេ គេច្រៀងៗទៅ គេរាំសិល្បៈគេណា៎ សិល្បៈគេស្លៀកខ្មៅ ពាក់ខ្មៅ ។

ប្រុញ ៖ មានកាយវិការអី គេធ្វើម៉េចដែរអ្នកមីង?

សូរី ៖ ចាស៎ មានកាយវិការ មិនចេះទេ ។

ប្រុញ ៖ គេធ្វើជាលក្ខណៈថាដូចយើងរាល់ថ្ងៃ ឬក៏យ៉ាងម៉េចដែរ?

សូរី ៖ ទេ! ដូចមិនដូចទេ ។

ប្រុញ ៖ ភាគច្រើនគេអបរំយើងពីអីគេវិញអ្នកមីង សម័យដែលគេធ្វើសិល្បៈហ្នឹង?

សូរី ៖ គេអបរំ ឲ្យស្មោះត្រង់ជាមួយអង្គការ ។

ប្រុញ ៖ ចម្រៀងគេវិញ ភាគច្រើនគេផ្តោតលើអីគេមីង?

សូរី ៖ មិនដឹងទេ ភ្លេចហើយ យូរពេក សមមិត្តគេច្រៀងអីចុះឯង យូរពេក យើងមិនស្គាល់ទេ មិនដឹងទេ គេច្រៀងពីសមមិត្ត អត់ដឹងថាស្អីគេទេ មិនចេះទេ ។

ប្រុញ ៖ ចុះនៅហ្នឹងដែលហូបខ្វះខាតទេ នៅត្រពាំងថ្ម និយាយរឿងបាយ?

សូរី ៖ អត់មានបាយទេ ហូបបបរ ។

ប្រុញ ៖ ចុះមានកងខ្លះគេបានហូបបាយទេអ្នកមីង?

សូរី ៖ មានកងខ្លះគេបានហូបដឹង ។

ប្រុញ ៖ ហ្នឹងមកពីមេកងយើង ឬម៉េចដែរ?

សូរី ៖ មិនដឹងមកពីខាងណាទេ ប៉ុន្តែដឹងថាកងខ្ញុំ ហូបបបរនោះឯង ។

ប្រុញ ៖ ដោយសារយើងធ្វើតិចជាងគេ ឬម៉េចដែរ?

សូរី ៖ មិនមែនទេ មិនដឹងកងអីគេទេ ឲ្យហូបតែបបរ ។

ប្រុញ ៖ អ្នកខ្លះថាបានហូបបាយអីចឹង ដោយសារគេធ្វើបានបីម៉ែត្រគូប ហើយអ្នកមីងពីរម៉ែត្រគូបកន្លះ គេអត់ឲ្យហូបបាយ ឬក៏យ៉ាងម៉េច?

សូរី ៖ កាលនេះបងយោង បីម៉ែត្រគូបដូចតែគ្នាហ្នឹង ដល់យូរៗទៅ ដូចកម្លាំងយើងថយ រែកកាន់តែខ្សោយទៅ បានចុះមកពីម៉ែត្រគូប ពីរនាក់ប្រាំម៉ែត្រគូប ។

ប្រុញ ៖ អីចឹងអត់ដែលបានហូបបាយទេ?

សូរី ៖ ទេ! មិនដែលបានហូបបាយទេ ណាបបរគេរឹងដែរនោះ ។

ប្រុញ ៖ អាហ្នឹងនៅត្រពាំងថ្មអ្នកមីង?

សូរី ៖ ត្រពាំងថ្ម នៅណាំតាវ ។

ប្រុញ ៖ មកណាំតាវ មកយូរទេអ្នកមីងមកធ្វើការនៅណាំតាវ?

សូរី ៖ មិនដឹងយូរប៉ុណ្ណាទេ មិនដឹងទេ ។

ប្រុញ ៖ ចេញពីត្រពាំងថ្មមក មកណាំតាវ?

សូវី ៖ ចេញពីត្រពាំងថ្មយប់អ៊ីចេះទៅ ដល់ព្រឹកឡើងលើកណាំតាវ លើកពីត្រពាំងថ្មចាក់ទៅអ៊ីចេះ ចេញតែយប់ ។

ប្រុញ ៖ ហើយណាំតាវហ្នឹង ធ្វើហត់ទេអ្នកមីង?

សូវី ៖ ដូចតែគ្នានៅត្រពាំងថ្មដែរ ប៉ុនតែគ្រាន់ថា គ្រាន់តែចូលខ្សែត្រៀមណាំតាវ ខ្សែត្រៀមបីម៉ែត្រគូប ។

ប្រុញ ៖ ធ្វើនៅណាំតាវហ្នឹង មានទឹកអីម៉េចដែរមីង?

សូវី ៖ ទឹកលួចដងអីចុះឯង មានគេប្រាប់ថាទឹកស្រះនៅណោះអី ក៏យើងមកដងទៅណា ។

ប្រុញ ៖ លួចដង ដូចកាលនៅត្រពាំងថ្មដែរ?

សូវី ៖ ចាស៎

ប្រុញ ៖ ហើយចុះឆ្ងាយទេអ្នកមីង?

សូវី ៖ ឆ្ងាយណាដង! យ៉ាងអន់ក៏២គីឡូកន្លះដែរ បើនៅត្រពាំងថ្មមានទឹកគ្រាន់ដែរ បើនៅនោះ ២គីឡូកន្លះមក ។

ប្រុញ ៖ កន្លែងដែលយើងទៅដងទឹក គេហៅថាស្រះអីដែរ?

សូវី ៖ មិនហ៊ានសួរគេ ស្រះគេ ប៉ុនទឹកគេល្អក់ដែរ ទឹកគេអត់ថ្លាទេ ។

ប្រុញ ៖ ចុះពេលដែលធ្វើនៅណាំតាវ ហូបបបរដូចនៅត្រពាំងថ្មដែរ?

សូវី ៖ ហូប ប៉ុនមានថ្ងៃណារីងដែរតើ បបរគេរាងរីងគ្រាន់ណា៎ ។

ប្រុញ ៖ ចុះយើងធ្វើដល់បីម៉ែត្រគូបហើយ គេអត់ឲ្យបាយអីហូបទេ?

សូវី ៖ គ្មានបាយទេ មិនដែលបានហូបបាយទេ ។

ប្រុញ ៖ ចុះមានជម្រកអីត្រឹមត្រូវទេ?

សូវី ៖ ទេមិនមែនទេ ថានៅក្រោមដើមស្វែង ក្រោមដើមដើងគោ ។

ប្រុញ ៖ ណាំតាវហ្នឹងគេធ្វើមនុស្សច្រើនទេអ្នកមីង?

សូវី ៖ មនុស្សច្រើនណា៎ ខាងយើងនេះក៏ច្រើន ខាងគេចេញមកពីណោះក៏ច្រើន ។

ប្រុញ ៖ ប្រហែលប៉ុន្មានពាន់ ប៉ុន្មានម៉ឺននាក់ទៅអ្នកមីង?

សូវី ៖ មើលទៅឃើញតែខាប់ៗ គេថាជាងមួយពាន់ៗ ក៏ថាទៅតាមគេ ខាងគេជាងមួយពាន់ ខាងយើងណោះជាងមួយពាន់ដែរ ។

ប្រុញ ៖ ចុះនៅហ្នឹងមានជំងឺអីច្រើនទេ ដល់ពេលយើងធ្វើការធ្ងន់យ៉ាងហ្នឹង?

សូរី ៖ មិនដែលឃើញថាសាប់នៅហ្នឹងមុខយើងទេ តែឃើញឈឺ ដូចថាយកទៅពេទ្យ ប៉ុន្តមិនដែលឃើញមកវិញទេ ។

ប្រុញ ៖ ចុះដែលពួកគេនិយាយថា មានស្លាប់អីច្រើនទេនៅណាំគាវហ្នឹង?

សូរី ៖ គេមិនដែលនិយាយទេ ដឹងតែឈឺយកទៅពេទ្យ គេមិនដែលយកទៅថ្ងៃទេ គេយកទៅតែយប់ៗណា ដូចថាយើងដេកបន្តៗគ្នា កងអានានឯងគេយកទៅដេកពេទ្យ មិនដឹងថាអ្នកណា បើយើងអត់ស្គាល់គេ យើងស្គាល់តែក្នុងមួយកងយើងនេះ យើងស្គាល់តែមួយក្រុមយើង ថាច្បាស់គ្នាប៉ុណ្ណេះនាក់ៗ ។

ប្រុញ ៖ នៅណាំគាវហ្នឹងពីណាគេអ្នកគ្រប់គ្រងអ្នកមីង?

សូរី ៖ អត់ស្គាល់គេទេ ។

ប្រុញ ៖ មេកងយើងក៏អត់ស្គាល់ដែរ?

សូរី ៖ អត់ស្គាល់ទេ ។

ប្រុញ ៖ អ៊ីចឹងមេកងអត់ដែលមកហៅយើងប្រជុំអីទេអ្នកមីង?

សូរី ៖ ទេ! មេកងគេហៅ ជួនកាលគេហៅ ប៉ុន្តយើងអត់ស្គាល់គេ ខ្ញុំស្គាល់តែបងឡាចមួយ ប្រធានមេកងនៅភូមិក្រោម ប្រធានយោធា តែស្រីទេណា៎ គាត់ក្លាប់នៅណាំគាវ ។ គាត់នៅម៉ាជួរស្ទឹងកំបុតមិនដឹង ប៉ុន្តប្រហែលគាត់ស្លាប់ហើយមិនដឹង គាត់ចិត្តល្អណាស់ គាត់ប្រធានកងរយដែលខ្ញុំទៅណាំគាវ ជួបប្រធានចិត្តល្អ ប្រធានកងរយ អត់ដែលចេះដេរអីទេ កាលខ្ញុំនៅត្រពាំងថ្មឡ តែក្រក្រោក មេកងយើងគេដេរណាថាអ៊ីចេះអ៊ីចុះទៅណា បើបងឡាចគាត់អត់ដែលដេរទេ មួយទៀតឈ្មោះបង ស គាត់គ្រុនសាប់ គាត់កូនអ្នកស្រុករោគ គាត់ស្រី ។

ប្រុញ ៖ គាត់នៅណាំគាវហ្នឹង?

សូរី ៖ ចាស៎ គាត់កូនអ្នកស្រុករោគ ពេលគាត់ដួសបបរ គាត់ដើរមើលគេអ្នកស៊ីបបរអ៊ីចេះទៅ សួរគាត់ថា បងនេះឈ្មោះបងអី ថាឈ្មោះបង ស មានតែបង ស និងបងឡាច នោះឯងដែលជិតល្អ ក្រៅពីនោះគេចិត្តអត់ល្អទេ ។

ប្រុញ ៖ បងស ហ្នឹងគាត់មេកងគេម៉េចដែរ?

សូរី ៖ គាត់សមាជិកកងធំ ។

ប្រុញ ៖ អ៊ីចឹងស្ថិតនៅក្រោមបងឡាច?

សូរី ៖ ទេ! បងឡាចនេះ គាត់បន្ទាប់ពីបងមកទៀត ។

ប្រុញ ៖ អ៊ីចឹងបងស ធំជាងបងឡាច?

សូរី ៖ ចាស៎ បងឡាចនេះដូចជាកង៩០នាក់អ៊ីចឹង ពុគាត់និយាយថា ៩០នាក់ ។

ប្រុញ ៖ អ៊ីចឹងគាត់ប្រធានកងនៅណាំតាវហ្នឹងដែរ បង ស?

សូរី ៖ ចាស៎ ប៉ុន បងស គាត់ស្លាប់ហើយ ។ កាលដែលវៀតណាមចូល ខ្ញុំជួបបងសីត្ថ ខ្ញុំសួរគាត់ គាត់ថា បងស ស្លាប់ហើយ ក្នុគឈាមកាលសម័យ៣ឆ្នាំមក ។

ប្រុញ ៖ គាត់ទើបតែស្លាប់ក្រោយដែរអ៊ីចឹង?

សូរី ៖ ស្លាប់ពេលវៀតណាមចូលបាន២ឆ្នាំ គាត់នៅនារី ប៉ុននារីនៅអាយុ៣៦ គាត់អាយុច្រើន ដែរ ហើយគាត់សូវធ្វើបាបទេ ដូចជាខ្ញុំអ៊ីចេះអ៊ី អត់សូវមានកម្ចាំងកាប់ កាប់នៅក្រោយគេអ៊ីចឹង គាត់ស្រណោះ គាត់មិនបានជួយយើងទេ តែគាត់មានចិត្តល្អ បើកាលដែលខ្ញុំនៅត្រពាំងថ្ម ឯណោះ អានាងដែលវាជាប្រធានកងថា កាប់ឲ្យលឿនទៅ គ្រាន់តែប៉ុណ្ណេះធ្វើទើតៗមិនចេះ រួច ។

ប្រុញ ៖ គាត់លើកទឹកចិត្តយើងដែរអ្នកមីង?

សូរី ៖ ហ្នឹងហើយគាត់លើកទឹកចិត្តយើង ជាពិសេសបងឡាច ។

ប្រុញ ៖ នៅហ្នឹងគេហៅប្រជុំញឹកញាប់ទេអ្នកមីង?

សូរី ៖ ទេ! គេមិនសូវដែលហៅទេ ។

ប្រុញ ៖ ចុះគេមានហៅប្រជុំទិតៀនគ្នាទេ?

សូរី ៖ មានតើ ប៉ុនយូរបានគេប្រជុំទិតៀនគ្នា ។

ប្រុញ ៖ នៅណាំតាវ?

សូរី ៖ ហ្នឹងហើយ គេប្រជុំដូចថាគេជំរុញឲ្យតែយើងធ្វើការណា កុំឲ្យយើងខ្ជិលច្រអូស បើគេប្រជុំ គេសួរយើងថាហូបឆ្អែតទេ យើងឆ្លើយថាឆ្អែតទៅណា ហូបឆ្ងាញ់ទេ? ឆ្ងាញ់ ដេកលក់ទេ? លក់ ។

ប្រុញ ៖ និយាយឲ្យចំគេដឹកមុខសំណួរឲ្យយើងឆ្លើយព្រមរហូត?

សូរី ៖ ចាស៎ ឆ្លើយតាមគេទៅណា បើទាំងអស់គ្នាឆ្លើយថាឆ្ងាញ់ យើងឆ្លើយថាស៊ីមិនឆ្ងាញ់ ខ្លាច គេយកទៅវ៉ៃចោល មិនហ៊ានទេ អ្នកណាហ៊ានឆ្លើយអ៊ីចុះ ។

ប្រុញ ៖ នៅណាំតាវហ្នឹងស្លាប់ច្រើនទេអ្នកមីង?

សូរី ៖ អត់ដែលឃើញឈឺស្លាប់នៅនោះទេ បើឈឺគេប្រាប់ថាគេយកទៅពេទ្យហើយ ។

ប្រុញ ៖ នៅហ្នឹងមុនដំបូងគេឲ្យធ្វើប៉ុន្មានម៉ែត្រ?

សូរី ៖ ធ្វើបីម៉ែត្រគូប ។ ដល់ពេលក្រោយមកមើលទៅថាវាឡើងកាន់តែខ្ពស់ៗ ទៅ២ម៉ែត្រគូបកន្លះ ខ្ញុំពីរនាក់បងយោង បងយោងប្រពន្ធបងយ៉េង ។

ប្រុញ ៖ ហ្នឹងនៅណាំគាវ?

សូរី ៖ ចាស៎ នៅត្រពាំងថ្មខ្ញុំដៃគូមួយគាត់តាំងពីនេះទៅ គាត់ស្រណោះខ្ញុំ គាត់និយាយប្រាប់ខ្ញុំថា នៅភូមិឯណោះ បងអេងស្លាប់អស់ គាត់សួរថាបងឯងធ្វើអី បងយោងថាកុំនិយាយអី បងអេង សាស្រ្តាចារ្យថាអីចេះ បងស្រីគាត់ណា សាស្រ្តាចារ្យនៅភ្នំពេញ គាត់ជម្លៀសមក ជាមួយបងប្អូនគាត់ គេដឹងទៅ ក៏គេយកទៅវ៉ៃចោល ខ្ញុំមិនហ៊ានសួរអីគាត់ទេ សួរតែប៉ុណ្ណោះ ឯង គាត់និយាយប្រាប់អស់ គាត់ប្រាប់ថា បើសិនជាបងស្លាប់ទៀត ដាច់ពូជហើយ នៅតែ បងម្នាក់ឯង ហើយបានគាត់សុខចិត្តលើកទំនប់ ដល់នេះទៅខ្ញុំនឹកឃើញស្រណោះគាត់ មានគេ ទូលស្វាយមក គេបេះស្វាយបានប្រហែល៨ផ្លែ ស្វាយខ្ចីយើង ខ្ញុំថាពូអើយដូរស្វាយនឹង ក្រវិលឲ្យខ្ញុំមក ក្រវិលខ្ញុំមួយជី គាត់ថាអូនឯងយកស្វាយប៉ុន្មាន ឲ្យខ្ញុំ៦មក ពូឯងយកពីរទៅ ខ្ញុំយកតែ៦ផ្លែទេ ដល់អ៊ីចឹងទៅគាត់ស្រណោះខ្ញុំថា មានតែខ្ញុំកូនប្រជាជនចាស់មែន តែគេធ្វើ បាបដូចប្រជាជនមកពីភ្នំពេញ ខ្ញុំថាបងយោង ខ្ញុំទើបតែមកដល់ពីសៀមរាប ច្បាប់ខ្ញុំមួយខែ ទៅមើលបានមួយអាទិត្យ គេឲ្យខ្ញុំមក គេបញ្ជូនខ្ញុំមក ។

ប្រុញ ៖ អ៊ីចឹងទូទៅប្រជាជនថ្មីគេធ្វើបាបជាងប្រជាជនចាស់ហើយតាមមើលទៅ?

សូរី ៖ បែបវាគិតថាអ៊ីចុះហើយ ។

ប្រុញ ៖ គេធ្លាប់ឲ្យធ្វើការធ្ងន់ជាងប្រជាជនចាស់?

សូរី ៖ មែនហើយ ដូចថាយើងមាននិន្នាការណា ច្រើនតែអ្នកថ្មីដែលស្លាប់ ដូចថាមិនសូវធ្វើការ ធ្វើអីណឹងណា ។

ប្រុញ ៖ ចុះពេលហ្នឹងគេមានឲ្យយើងរៀបការទេ?

សូរី ៖ មានតើអូន គេចាប់ដៃចាប់អីទៅ ។

ប្រុញ ៖ ការម្តងប៉ុន្មានគូដែរអ្នកមីង?

សូរី ៖ ២០ ៦០ អាបិទវគ្គលើកក្រោយ ៦០គូ ។

ប្រុញ ៖ នៅណាំគាវ ឬក៏នៅណា?

សូរី ៖ នៅអាងត្រពាំងថ្ម គេមិនដឹងឲ្យទៅចាប់ដៃណាទេ ដឹងតែ៦០គូ ។

ប្រុញ ៖ ៦០គូហ្នឹង យើងស្ម័គ្រចិត្ត ឬគេបង្ខំរៀបការ?

សូរី ៖ មិនដែលដឹងទេ មិនដែលហ៊ានសួរគេទេ ។

ប្រុញ ៖ ដែលមានអង្គការគេប្រកាសថាត្រូវឲ្យមានរៀបការហ្នឹងប្ដូរទេ?

សូរី ៖ គេសួរយើងដែរ បើយើងយកបានគេឲ្យ ដូចថាអានាងឯងស្មើខ្ញុំអីចេះទៅ បើថាសុខចិត្ត នៅជាមួយគ្នាហើយ ដូចថាការមួយលើកនេះ២០គូ អីចេះទៅ អ្នកខ្លះចេញមក វង្វេងរកគូ ខ្លួនឯងមិនឃើញ អត់ស្គាល់គូខ្លួនឯង ចេះតែការៗទៅ ឃើញមិនដែលមានអ្នកណាបានគ្នា សុខដុង វៀតណាមចូលក៏លែងគ្នាអស់ ការបួនដប់គូ ក៏លែងគ្នាអស់រលីង ។

ប្រុញ ៖ ដល់ពេលការហើយ គេឲ្យយើងនៅជាមួយគ្នាដែរអ្នកមីង?

សូរី ៖ ទេ! គេមិនឲ្យនៅជាមួយគ្នាទេ ដូច ខ្ញុំ ជួយ រែកទំនប់ជាមួយខ្ញុំ ការរួចមិនទាំងឲ្យនៅ ជាមួយគ្នាផង ប្ដីទៅផ្សេង ដល់ពេលវៀតណាមចូល ប្រពន្ធទៅផ្សេង ប្ដីទៅផ្សេង មួយគេ ទៅការប្ដីទៅ ប្ដីទៅការប្រពន្ធទៅ ។

ប្រុញ ៖ ពេលដឹក មានពួកជនជាតិវៀតណាមទេអ្នកមីង?

សូរី ៖ មិនដឹងជាជនជាតិអីទេ មានអ្នកណាសៗគេថាយួន ឬចិន ចេះតែថាតាមគេដែរ តែអ្នក ភ្នំពេញមកដែរ តែមានខ្មៅ ។

ប្រុញ ៖ ចុះមានដឹងថាពួកយួនត្រូវគេសម្លាប់ ត្រូវអីទេអ្នកមីង?

សូរី ៖ បើយួនច្រើនតាមភូមិអីចេះទៅវិញ ។

ប្រុញ ៖ យួនបាននៅក្នុងភូមិណឹងដែរ?

សូរី ៖ យួននៅក្នុងភូមិច្រើន ជនជាតិដែលគេនិយាយប៉ែឡាំៗ គេថាព្រះត្រពាំង ដូចថានៅក្នុងស្រុក ភូមិនៅក្នុងខេត្តយើងអីចេះណា ដូចថាខេត្តណាមានជនជាតិចាមអីតិចៗ ជនជាតិភាគតិច ណា ។

ប៊ុនថន៖ កម្ពុជាក្រោម?

សូរី ៖ អ៊ី! កម្ពុជាក្រោមមាន ។

ប្រុញ ៖ ពេលពួកខ្មែរក្រហមចូល ពួកហ្នឹងម៉េចដែរ?

សូរី ៖ យកទៅសម្លាប់អស់ ។

ប្រុញ ៖ ពួកវៀតណាមគេយកទៅសម្លាប់អស់ ពេលខ្មែរក្រហមចូល?

សូរី ៖ ហ្នឹងហើយ បងសំបូរនៅភូមិកណ្ដាល កូនប៉ុនអានាងនោះហើយ កូនធំហើយ ដល់តែប្រពន្ធ គាត់ខ្មែរកម្ពុជាក្រោមអីចេះឯង យកទៅសម្លាប់ទាំងប្ដីទាំងប្រពន្ធទាំងអស់ មានដែរយកទៅ សម្លាប់អស់ ។

ប្រុញ ៖ សម្លាប់ជនជាតិវៀតណាមណឹង សម្លាប់តាំងពីចូលភ្លាមរហូតដល់ចុងក្រោយម៉េចដែរ?

សុរី ៖ ដល់ចុងក្រោយ ដល់ពេលខ្ញុំចាប់អានត្រពាំងថ្មមក ខ្ញុំមកលេងភូមិបាន១០ថ្ងៃ មានឈ្មោះពូយ៉េន អ្នកភ្នំពេញ ប្រពន្ធកើតកូននោះ ពូយ៉េន អ៊ីដន មីងមិនសូវស្គាល់ទេក្រុមគ្រួសារគាត់ ប៉ុនគាត់មកលាម៉ែខ្ញុំ មកលាថាអ៊ំអើយកូនមកជម្រាបលាហើយ គេឲ្យកូនទៅស្រុក ទៅស្រុកអី គេថាយកទៅសម្លាប់យ៉ាំងអស់រលីង ជនជាតិកម្ពុជាក្រោមណា ប្រពន្ធទើបកើតកូនបាន៣ថ្ងៃ កូនងាំក្រហមងងាល ប្ដីឲ្យប្រពន្ធបីកូន គាត់ទូរភ្លួយ ប្ដីរែកកន្ទបអីណា ។

ប្រុញ ៖ គេសម្លាប់នៅជិតភូមិហ្នឹងម៉េចដែរ?

សុរី ៖ ទេមិនដឹងទេ ដល់នេះទៅ ខ្ញុំឮម៉ែខ្ញុំថា គេមានឲ្យទៅស្រុកឯណា គេយកទៅសម្លាប់អស់រលីង ។ ម៉ែខ្ញុំមិនដែលបានធ្លាប់ឃើញទេ ឮតែគេថា គាត់ថាតាមតែគេ ជួនកាលគាត់ឮតែពួកឈ្លបវានិយាយគ្នាណា៎ ។

ប្រុញ ៖ មានចាមដែរតើនៅសម័យហ្នឹង?

សុរី ៖ បែបមាន យើងមិនសូវស្គាល់ច្បាស់ណា ដូចថាយើងស្គាល់ខ្មែរកម្ពុជាក្រោម ព្រោះបងយ៉េនគាត់និយាយប៉ែឡាំៗទាំងប្ដីទាំងប្រពន្ធ ។

ប្រុញ ៖ អ៊ីចឹងពេលដែលចូលមកភ្លាមជនជាតិវៀតណាមគេសម្លាប់ចោល ចុះអ្នកធ្លាប់ធ្វើការនៅសម័យ លន់ នល់ ម៉េចដែរ?

សុរី ៖ អត់ដឹងទេ ពួកអីចេះៗម៉េចដឹង បើទៅកងចល័តសមរភូមិមុខអស់នោះ ។

ប្រុញ ៖ ចូលភ្លាម ខ្មែរក្រហមមានប្រមូលអីខ្លះទៅអ្នកមីង?

សុរី ៖ ប្រមូលមាសប្រមូលប្រាក់អស់ កងដៃកងអី ដូចថារបស់នេះអី គេមិនប្រមូលទេ គេឲ្យយើងយកទៅដាក់អ្នកណាមាន បើអ្នកណាមានហើយលាក់ក៏គេយកប្រដាប់ឆ្លុះនោះឃើញ គេថាអ៊ីចេះ ។

ប្រុញ ៖ គេគំរាមយើងថា គេមានប្រដាប់ឆ្លុះមើល ។

សុរី ៖ ចាស៎ ម៉ែខ្ញុំគាត់មកកាស់ពាងឲ្យគេអស់ គាត់ដាក់ក្នុងពាងកប់ហើយ គាត់មកកាស់ឲ្យគេអស់ ។

ប្រុញ ៖ គោក្របីម៉េចដែរ?

សុរី ៖ គោក្របីមានឯណា គេយកទៅដាក់រួមអស់ អ៊ំខ្ញុំគោតិចណាស់អី ខ្ញុំគ្រាន់តែមាន៥-៦ អស់ទាំងអស់នោះឯង ។

ប្រុញ ៖ ពេលអ្នកមីងចូលមកស្រុក ខ្មែរក្រហមបានជម្លៀសអ្នកភូមិចេញពីភូមិអស់ហើយ?

សុរី ៖ គេឲ្យទៅនៅណោះ ម៉ែខ្ញុំគេឲ្យទៅច្រូតតាមក្រុម ទៅច្រូតឆ្ងាយ ។

ប្រុញ ៖ ខ្ញុំសូមសួរទៅខាងមុខ ពេលអ្នកមីងធ្វើនៅណាំគាវហើយ អ្នកមីងធ្វើណាទៀតទៅ?

សូរី ៈ ចេញមកពីណោះវិញ គេឲ្យធ្វើនៅដើមពោធិ៍បីដើម បានប្រហែល៦ថ្ងៃ មិនទាន់ស្គាល់ប្រធានកងច្បាស់ផង ដល់នេះទៅគេឲ្យខ្ញុំមកធ្វើទំនប់បង្ហើយ៣ថ្ងៃទៀត នេះអាទំនប់កាច់ជ្រុងជ្រោយសំរោង ។

ប្រុញ ៈ គេហៅទំនប់អីទៅ?

សូរី ៈ ទំនប់កំបោរស្រែះនេះ មកធ្វើនេះបាន៣ថ្ងៃរួច បានគេបញ្ជូនឲ្យទៅច្រូតស្រូវណោះ ខ្ញុំទើបទៅមិនទាន់ទាំងបានច្រូតផង ក៏វៀតណាមចូល ។

ប្រុញ ៈ អ៊ីចឹងធ្វើនៅដើមពោធិ៍៣ដើម បានតែ៦ថ្ងៃទេ?

សូរី ៈ ចាស៎

ប្រុញ ៈ ទៅណឹងគេឲ្យធ្វើអីគេអ្នកមីង?

សូរី ៈ គេឲ្យលើកប្រព័ន្ធភ្លឺស្រែ បើយើងថាស្រែប្រាំងនេះណាបានតែ៦ថ្ងៃ គេឲ្យមកទំនប់នេះ៣ថ្ងៃ គេឲ្យទៅច្រូតស្រូវនៅស្រុកក្រោម ដលទៅច្រូតព្ធថាវៀតណាមចូល ដូចថាថ្ងៃ១៣កើត ខែភ្លឺក៏ពួកបងប្អូនប្រជាជនថ្មី ពួកបងសែនស្គាល់គាត់ថា អាវីអើយមក នែ៎វៀតណាមចូលមកហើយ តោះយើងទៅម៉ែទៅឪយើង ថាអ៊ីចេះ គាត់បបួលខ្ញុំមក ខ្ញុំមកទាន់ដែលគេយកពុកខ្ញុំទៅសម្លាប់តើ ។

ប្រុញ ៈ ឪពុកបង្កើតរបស់មីង?

សូរី ៈ ចាស៎

ប្រុញ ៈ គេយកទៅសម្លាប់នៅណា?

សូរី ៈ ចាប់ក្នុងភូមិជ្រោយក្បៀងហ្នឹងឯង ។

ប្រុញ ៈ ម៉េចបានគេចាប់គាត់អ្នកមីង?

សូរី ៈ គេថាគាត់ប្រវត្តិទាហាន ។

ប្រុញ ៈ ទាហាន លន់ នល់?

សូរី ៈ ចាស៎ ទាហាន ១៨ខែ ម៉ែខ្ញុំគាត់ប្រាប់ ។

ប្រុញ ៈ ទាហានជាប់កាតព្វកិច្ចរបស់ លន់ នល់?

សូរី ៈ ទាហាន១៨ខែ មិនដឹងទាហានណាទេ ។ ឲ្យតែប្រវត្តិទាហានមួយថ្ងៃ ក៏គេថាទាហានដែរ ។

ប្រុញ ៈ ចុះគេចាប់គាត់សម្លាប់នៅឆ្នាំណាអ្នកមីង?

សូរី ៈ ចាប់សម្លាប់បានប្រហែល២ខែ ក៏វៀតណាមចូល ។

ប្រុញ ៈ ចុះគេអត់មានសួររកបណ្តាញកូនចៅគាត់ម៉េចទេ?

សូរី ៖ សួរតើ បានអីខ្ញុំ ឪមីនេះផង អីផង បងប្អូនខ្ញុំនៅនេះ ថាមានទាក់ទងអីនឹងកូនចៅទេ បើឪពុកស្លាប់ទៅហើយ ចេះតែជួយលាក់គ្នាទៅណា បាននៅទៅ កុំអីគេយកសម្លាប់ទាំងម៉ែខ្ញុំ បើសិនជាវៀតណាមកុំឆាប់ចូល ក៏ងាប់ទាំងអស់នោះឯង ។

ប្រុញ ៖ អ៊ីចឹងខ្មែរក្រហមបានស្រាវជ្រាវរកប្រវត្តិយើងដែរ តែយើងបានគេចខ្លួនបុម៉េច?

សូរី ៖ ទេ! យើងមិនបានគេចខ្លួនទៅណាទេ ចុះគេចទៅណាបើឪពុកស្លាប់ហើយនោះ ។

ប្រុញ ៖ ចុះម្ដាយរបស់មីង?

សូរី ៖ ម៉ែខ្ញុំនៅរាល់ថ្ងៃទេ នៅប៉ុនគាត់ចាស់ ៨០ជាងហើយ ។

ប្រុញ ៖ អ៊ីចឹងចាប់គាត់សម្លាប់បាន២ខែ បានវៀតណាមចូលហ្នឹងទៅ?

សូរី ៖ វាមិនដល់២ខែទេ ដែលគេសម្លាប់ពុកណា ។

ប្រុញ ៖ មានគេឆ្លើយប្រាប់ម៉េចដែរបានខ្មែរក្រហមដឹង?

សូរី ៖ បែបមានដឹង ខ្ញុំមិនដឹងដែរ ឈ្លបគេក្នុងភូមិគេឆ្លើយ ។

ប្រុញ ៖ គេសម្លាប់ឲ្យយើងឃើញទេពេលហ្នឹង?

សូរី ៖ ទេ! គេគ្រាន់តែចាប់ចងក្នុងផ្ទះ គ្រាន់តែយើងឃើញគេចាប់ចង ប៉ុនយើងមិនហ៊ាននិយាយអីទេ ។

ប្រុញ ៖ មកចុងក្រោយមានអ្នកដែលសម្លាប់ថាជាប់ប្រវត្តិទាហានលន់ នល់ ច្រើនទេអ្នកមីង?

សូរី ៖ មានតើ មានគេចាប់ មិនមែនទាហានលន់ នល់ ទេ ម៉ែគាត់ថាទាហានសម្ដចសីហនុ ១៨ខែ ថាទាហានសម្ដេច ពុកគាត់និយាយថាអ៊ីចុះឯង ។

ប្រុញ ៖ ពេលដែលគេចាប់ គាត់នៅធ្វើអី?

សូរី ៖ ពេលដែលគេចាប់ គាត់នៅមើលគោ ធ្វើស្រែ គេឲ្យយើងទៅភ្ជួរ យប់ឡើងក៏គេចាប់ ។

ប្រុញ ៖ ដល់ពេលវៀតណាមវៃចូលហើយ មីងមកណាវិញ?

សូរី ៖ មកនៅក្នុងភូមិចាស់នេះវិញ ។

ប្រុញ ៖ ចុះបងប្អូនមីងម៉េចដែរ មកជួបជុំគ្នាទេ?

សូរី ៖ គ្មានទេ បងប្អូនខ្ញុំងាប់អស់ហើយ នៅតែម៉ែខ្ញុំមួយហើយនិងខ្ញុំនេះឯង ។

ប្រុញ ៖ អ៊ីចឹងអ្នកភូមិពេលវៀតណាមចូលមក ត្រឡប់មកភូមិវិញទាំងអស់?

សូរី ៖ ត្រឡប់មកវិញ សុទ្ធតែអ្នកភូមិនេះទាំងអស់ ។

ប្រុញ ៖ ពេលវៀតណាមចូល មានខ្មែរក្រហមចូលឆ្មក់ចូលអីទេ?

សូវី ៖ មានតើ ចូលឆ្នក់ម្ដងៗ ខ្ញុំមកគ្មានផ្ទះនៅទេ ខ្ញុំនៅក្រោមដើមចេកអ៊ីចេះឯង ផ្ទះធំ ក៏គេរើចេញអស់ ។

ប្រុញ ៖ ពេលវាចូលមកវាដែលកេណ្ឌប្រជាជនយើងទេ?

សូវី ៖ អត់ទេ លើកក្រោយមកវាមិនដែលកេណ្ឌទេ ប៉ុនចូលមកវាបាញ់ កាលណោះបាញ់នេះ ផាប់ស្រីៗ២-៣នាក់អ៊ីចេះឯងកាលណោះ ប៉ុល ពត ។

ប្រុញ ៖ ពេលដែលចាប់ផ្ដើមសន្តិភាព តាំងពីវៀតណាមចូលមកបានយូរទេអ្នកមីង?

សូវី ៖ បាញ់២-៣ដងដែរ វាចូលមករំខាន២-៣ដងដែរ ប៉ុនវាមិនបានជាផលប្រយោជន៍អីដែរ ។

ប្រុញ ៖ អ្នកមីងមានអីចង់បន្ថែមទេ?

សូវី ៖ ទេ! អត់មានទេ អស់ហើយ មានតែប៉ុណ្ណេះឯង ។

«ចប់»